# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាអភិបូជានៅព្រះសហគមន៍ព្រះកុមារយេស៊ូ
# ទឹកខ្មៅចំពុន ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩
## ធ្វើឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់បន្តដំណើរនៅមុខ

**អត្ថបទទី១៖ ម៉ាកាបាយទី២ ៧,១-២.៩-១៤**

កាលជិតផុតដង្ហើម គាត់ទូលស្ដេចថា៖ «ព្រះករុណាជាស្ដេចពាល! ព្រះករុណាប្រហារជីវិតទូលបង្គំយើងខ្ញុំនៅពេលនេះ តែព្រះមហាក្សត្រនៃពិភពលោក នឹងប្រោសយើងឲ្យរស់ឡើងវិញ មានជីវិតអស់កល្បជានិច្ច ព្រោះទូលបង្គំយើងខ្ញុំស៊ូស្លាប់ដើម្បីគោរពវិន័យរបស់ព្រះអង្គ»។ ២មបា ៧,៩

**អត្ថបទទី២៖ ថេស្សាឡូនិកទី២ ២,១៦-៣,៥**

សូមព្រះអម្ចាស់ដឹកនាំចិត្តគំនិតបងប្អូន ឲ្យស្រឡាញ់ព្រះជាម្ចាស់ និងមានចិត្តស៊ូទ្រាំដែលព្រះគ្រីស្តប្រទានឲ្យ។ ២ថស ៣,៥

**ដំណឹងល្អ៖ លូកា ២០,២៧-៣៨**

ព្រះជាម្ចាស់មិនមែនជាព្រះរបស់មនុស្សស្លាប់ទេ គឺជាព្រះរបស់មនុស្សដែលមានជីវិត ចំពោះព្រះអង្គ មនុស្សទាំងអស់សុទ្ធតែនៅរស់។ លក ២០,៣៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ គេបង្កើតរឿងមួយដែលមិនមែនជារឿងពិត ដើម្បីសាកលមើលព្រះយេស៊ូបកស្រាយអំពីបញ្ហាជីវិតនៅស្ថានបរមសុខ។ ប្រសិនបើ រឿងដែលគេបាននិយាយកើតឡើងពិត យើងជឿថានៅស្ថានបរមសុខមហារញេរញៃ ដោយសារមានប្រពន្ធតែម្នាក់មានប្ដីប្រាំពីរនាក់ មានអ្នកដែលទាមទារថានេះជាប្រពន្ធរបស់គេរៀងៗខ្លួន។ ព្រះយេស៊ូមានចម្លើយមួយគឺ "**អ្នកទាំងនោះលែងស្លាប់ទៀតហើយ គឺគេបានដូចទេវទូតគេជាបុត្រធីតារបស់ព្រះជាម្ចាស់ ត្បិតគេមានជីវិតរស់ឡើងវិញ**" យើងមិនអាចនិយាយវែងឆ្ងាយអំពីជីវិតនៅស្ថានបរមសុខបាន ព្រោះគ្មានអ្នកណាដែលត្រលប់មកវិញទេ។ ប៉ុន្តែ យើងយល់ថាអ្វីដែលយើងមាននៅស្ថានបរមសុខ ទំនាក់ទំនងដែលយើងមាននៅលើផែនដីនេះទៅជាទំនាក់ទំនងថ្មីសុទ្ធ។ យើងទៅជាទេវទូត ជាបុត្រធីតារបស់ព្រះជាម្ចាស់ដែលភ្ជាប់នឹងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ដើម្បីរស់នៅអស់កល្បជានិច្ច។

សប្ដាហ៍មុន យើងបាននិយាយអំពីសន្តបុគ្គលទាំងឡាយដែលនៅស្ថានបរមសុខ ដែលមានឈ្មោះជាមួយព្រះជាម្ចាស់ហើយ និងដល់មនុស្សដែលនៅលើផែនដីនេះកំពុងត្រៀមខ្លួនដើម្បីរកឃើញសេចក្ដីសុខ។ នៅពេលយើងស្ដាប់អត្ថបទទីពីរ ណែនាំឲ្យយើងមានកម្លាំងដោយសារយើងឃើញនៅលើផែនដីនេះ ព្រះជាម្ចាស់គាំទ្រយើង ព្រះជាម្ចាស់ស្រឡាញ់យើង

ព្រះជាម្ចាស់បង្ហាញព្រះហឫទ័យប្រណីសន្តោសឲ្យយើង ព្រះជាម្ចាស់ធ្វើដំណើរជាមួយយើង ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះចំពោះយើង។ យើងពិចារណាអំពីជីវិតរបស់យើងនៅលើផែនដី អ្វីដែលកើតឡើងនៅទីនេះពេលយើងទៅស្ថានបរមសុខ ព្រះជាម្ចាស់នឹងសួរយើង**តើយើងបានធ្វើអ្វីខ្លះនៅលើផែនដី?** លោកប៉ូលបាននិយាយថា "**សូមបងប្អូនអធិដ្ឋានឲ្យយើងផង ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់បន្តដំណើរយ៉ាងឆាប់រហ័សតទៅទៀត និងបានរុងរឿងដូចនៅក្នុងចំណោមបងប្អូនដែរ**"។ សម្រាប់យើងដែលកំពុងចូលនៅក្នុងឆ្នាំសិក្សាថ្មី ឆ្នាំថ្មីនៃជីវិតរបស់ព្រះសហគមន៍ជាពេលវេលាដើម្បីគិតពិចារណាអំពីជីវិតយើងជាគ្រីស្តបរិស័ទ យើងធ្វើដូចម្តេចដើម្បីចូលនៅក្នុងគម្រោងការដែលសន្តប៉ូលមានពីដើមរៀងមក ណែនាំឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់បន្តដំណើរយ៉ាងឆាប់រហ័សតទៅទៀត និងបានរុងរឿងដូចនៅក្នុងដួងចិត្តរបស់យើង។ **តើយើងធ្វើដូចម្តេចដើម្បីទៅជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់?**

យើងធ្វើដូចម្តេច ដើម្បីឲ្យព្រះវិហាររបស់យើងទៅជាសញ្ញាសម្គាល់នៃជីវិតដែលយើងទទួលពីព្រះជាម្ចាស់។ ព្រះជាម្ចាស់មានព្រះជន្មគង់នៅ ព្រះជាម្ចាស់ធ្វើដំណើរជាមួយមនុស្សដែលមានជីវិត ជីវិតដែលយើងទទួលណែនាំឲ្យយើងពោរពេញដោយសេចក្តីសុខ។ ព្រះបន្ទូលដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ យើងធ្វើដូចម្តេចដើម្បីប្រកាស សម្រាប់យើងទាំងអស់គ្នាដែលរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ។ ព្រះសហគមន៍ ព្រះវិហារជាកន្លែងមួយ សំខាន់គឺយើងដែលជាគ្រីស្តបរិស័ទតាមកន្លែងដែលយើងនៅ យើងធ្វើដូចម្តេចដើម្បីឲ្យដំណឹងល្អរបស់ព្រះជាម្ចាស់ទៅដល់បងប្អូនទាំងអស់។ យើងធ្វើដូចម្តេច ដើម្បីបើកចិត្តគំនិតរបស់យើងឲ្យជីវិតរបស់ព្រះជាម្ចាស់ទៅដល់បងប្អូនឯទៀតៗ តាមព្រះសហគមន៍នីមួយៗគិតផ្ទាល់ខ្លួន យើងធ្វើដូចម្តេចដើម្បីសាបព្រោះឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាប់ផ្តើមធ្វើដំណើរនៅក្នុងដួងចិត្តរបស់មនុស្ស។ សាសនាយើងមិនមែនសម្រាប់តែគ្នាយើង យើងជាមហាគ្រួសារដែលចេះបើកដំណឹងល្អដល់មនុស្សយ៉ាងច្រើន។

ខ្ញុំបានឃើញផ្ទាល់ភ្នែក នៅតាមកន្លែងដែលខ្ញុំបានចាប់ផ្តើមប៉ុន្មានកន្លែង គឺមកពីគ្រីស្តបរិស័ទផ្ទាល់ មកពីយុវជនផ្ទាល់ដែលបានអញ្ជើញមិត្តភក្តិមកមើល។ គ្រីស្តទូតដែលមានសមត្ថភាពខ្ពស់ជាងគេ គ្រីស្តទូតដែលអាចណែនាំឲ្យបន្តដំណឹងល្អយ៉ាងច្បាស់លាស់ គឺបងប្អូនផ្ទាល់ដែលនៅតាមកន្លែងនីមួយៗ។ យើងត្រូវការគិត នៅរាជធានីភ្នំពេញយើងធ្វើដូចម្តេចដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ អាចមានឥទ្ធិពលថែមទៀតលើមនុស្សយ៉ាងច្រើន។ មណ្ឌលនិស្សិតរបស់យើង ឲ្យទៅជាពន្លឺមួយដ៏អស្ចារ្យសម្រាប់និស្សិតទាំងអស់ដែលទៅរៀននៅតាមសាកលវិទ្យាល័យនានា ឲ្យមណ្ឌលយើងទៅជាកន្លែងមួយពិសេសដែលណែនាំឲ្យយុវនិស្សិតថ្មី អាចស្គាល់ជីវិតជាគ្រីស្តបរិស័ទ។ ទោះបីគេមិនមែនជាគ្រីស្តបរិស័ទ ឲ្យយើងសាបព្រោះទៅគេកុំឲ្យ

យើងធ្វើចម្ងាយដែលៗយើងត្រូវការគិតថ្មី។ យើងត្រូវការគិតអំពីរបៀបថ្មី ដើម្បីឲ្យយើងសហការគ្នាច្រើនជាងឲ្យយើងមានឥទ្ធិពលនៃដំណឹងល្អ ឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់បន្តដំណើរ។ តួនាទីដែលយើងទទួលសម្រាប់ឆ្នាំថ្មីនេះ យើងធ្វើដូចម្តេចដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់បន្តធ្វើដំណើរ ដោយអង្គុយពិភាក្សាគ្នាដើម្បីសហការគ្នា។ យើងធ្វើដូចម្តេច ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះអម្ចាស់បន្តដំណើរយ៉ាងឆាប់រហ័សតទៅទៀត ពេលយើងចូលអភិបូជាយើងបានទទួលកម្លាំងដោយសារអភិបូជាជាប្រភព និងជាកំពូលនៃជីវិតរបស់យើងជាគ្រីស្តបរិស័ទ។ យើងទទួលកម្លាំងដើម្បីទៅមុខ ហើយយើងចែករំលែកជាមួយព្រះជាម្ចាស់អំពីជីវិតរបស់យើង ដោយទូលថាសូមព្រះអម្ចាស់ដឹកនាំចិត្តគំនិតបងប្អូនឲ្យស្រឡាញ់ព្រះជាម្ចាស់ និងមានចិត្តស៊ូទ្រាំនឹងអ្វីដែលព្រះគ្រីស្តប្រទានឲ្យ។ នៅពេលយើងតស៊ូហើយ យើងអាចទៅមុខបានដោយសារព្រះជាម្ចាស់ណែនាំឲ្យយើងរឹងមាំនៅក្នុងការតស៊ូ និងណែនាំឲ្យយើងស្រួលនៅក្នុងការប្រកាសដំណឹងល្អតទៅទៀត។ អាម៉ែន៕